01348401

E441/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 11 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យដាក់បង្ហាញខ្សែអាត់សំឡេង នៃចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ ដែលបានដាក់នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយមេធាវីការពារក្តី ខៀវ សំផន សុំឱ្យបញ្ជាក់អំពីអត្ថិភាពខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ជាដូចគ្នាជាមួយនឹងកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ("កំណត់ហេតុស្តាប់ចម្លើយ") នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយដែលអង្គជំនុំជម្រះបានសម្រេច ឬនឹងសម្រេចទទួលយកកំណត់ហេតុទាំងនោះធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ។ មេធាវីការពារក្តី ខៀវ សំផន ក៏បានស្នើដល់អង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញខ្សែអាត់សំឡេងទាំងនោះ ព្រមទាំងទទួលយកវាធ្វើជាភស្តុតាង និង ដាក់ទណ្ឌកម្មលើសហព្រះរាជអាជ្ញាចំពោះការខកខានក្នុងបង្ហាញខ្សែអាត់សំឡេង ព្រោះវាជាភស្តុតាងដោះបន្ទុក[1]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតប នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦[2]។

២. ដោយសាក្សីពីររូបនឹងមកផ្តល់សក្ខីកម្មក្នុងពេលឆាប់ៗខាងមុខនេះ ហើយកំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ គឺជាផ្នែកមួយនៃសំណើសុំរបស់ ខៀវ សំផន ក្នុងការឱ្យដាក់បង្ហាញកំណត់ហេតុទាំងនោះ នោះ អង្គជំនុំជម្រះ តាមរយៈអ៊ីម៉ែលថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦ បានបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីធ្វើការដាក់បង្ហាញខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយចំនួនមួយរបស់សាក្សី 2-TCW-960 និងកំណត់ហេតុស្តាប់ចម្លើយចំនួនបីរបស់សាក្សី 2-TCW-1065[3]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[1] សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យដាក់បង្ហាញ និង ទទួលយកខ្សែអាត់សំឡេង នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារ E441 ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ ("សំណើរបស់ ខៀវ សំផន")។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ ខៀវ សំផន សុំឱ្យដាក់បង្ហាញ និង ទទួលយកខ្សែអាត់សំឡេង នៅសំណុំរឿង ០០៣ និង ០០៤ ឯកសារ E441/1 ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់ ស.ព.អ")។

[3] អ៊ីម៉ែលពីមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនសហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E441/2.1 ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦។

បានអនុញ្ញាតឱ្យដាក់បង្ហាញខ្សែអាត់សំឡេងទាំងបួននេះ ហើយគ្រប់ភាគីបានទទួលការជូនដំណឹង នៅថ្ងៃទី ១២ និងទី ១៣ ខែ តុលា ឆ្នាំ ២០១៦[4]។

## ២. សារណា

### ២.១ សំណើរបស់ ខៀវ សំផន

៣. មេធាវីការពារក្តី ខៀវ សំផន អះអាងថាខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ដែលត្រូវបានធ្វើជាកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ទើបបានរកឃើញ កាលពីចុងខែសីហា ឆ្នាំ ២០១៦ នៅពេលដែលសហព្រះរាជអាជ្ញាបានដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយមួយ ដែលនៅក្នុងនោះអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បានលើកឡើងនូវដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះនៅខែ កញ្ញា ឆ្នាំ ២០១៥ ដែលតម្រូវឱ្យអ្នកស៊ើបអង្កេតថតសំឡេងនូវរាល់កិច្ចសម្ភាសន៍នៃការស្តាប់ចម្លើយ[5]។ មេធាវីការពារក្តីមិនបានដឹងថានៅក្នុងសំណុំរឿង ០០៣ និង ០០៤ មានខ្សែអាត់សំឡេងនូវរាល់កិច្ចសម្ភាសន៍នោះឡើយ[6]។ ការយល់ឃើញបែបនេះព្រោះ (១) កាលពីពេលមុន មេធាវីការពារក្តីធ្លាប់ស្នើសុំខ្សែអាត់សំឡេងនៃកំណត់ហេតុស្តាប់ចម្លើយមួយពីក្នុងសំណុំរឿង ០០៤ ហើយមេធាវីការពារក្តីត្រូវបានផ្តល់ដំណឹងថាការស្តាប់ចម្លើយទាំងនោះពុំមានថតជាសំឡេងនោះឡើយ (២) ប្រអប់ដែលបញ្ជាក់ថា ការស្តាប់ចម្លើយត្រូវបានថតសំឡេងនោះមិនត្រូវបានគូសឡើយ សម្រាប់កំណត់ហេតុនៃការស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ សម្រាប់សាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ និង (៣) សហព្រះរាជអាជ្ញា មិនដែលផ្តល់ដំណឹងដល់មេធាវីការពារក្តីទាក់ទិននឹងអត្ថិភាពនៃខ្សែអាត់សំឡេងទាំងនេះ នោះឡើយ បើទោះបីជាមេធាវីការពារក្តីបានធ្វើការត្អូញត្អែរជាច្រើនលើកអំពីនត្ថិភាពនៃខ្សែអាត់សំឡេងនៃកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ យ៉ាង

---

[4] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញខ្សែអាត់សំឡេងមួយក្នុងសំណុំរឿង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២ ឯកសារ D193/101 (សំណុំរឿង ០០៤) ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ("ការអនុញ្ញាតឱ្យដាក់បង្ហាញខ្សែអាត់សំឡេងក្នុងសំណុំរឿង ០០៤")។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញខ្សែអាត់សំឡេងបីនៃសំណុំរឿង ០០៣ ចូលទៅក្នុងសំណុំរឿង ០០២ ឯកសារ D100/36 (សំណុំរឿង ០០៣) ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦។

[5] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៣, ៥-៦។

[6] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៧-៨។

ណាក៏ដោយ[7]។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ដែលត្រូវបានធ្វើជាកំណត់ហេតុស្តាប់ចម្លើយ អាចប៉ះពាល់ដល់ភាពជឿជាក់បាននៃភ័ស្តុតាងរបស់សាក្សី ដូច្នេះ ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយនេះត្រូវធ្វើការដាក់បង្ហាញដល់មេធាវីការពារក្តី អនុលោមតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង និង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលព្រមជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[8]។

៤. មេធាវីការពារក្តី ខៀវ សំផន លើកឡើងទៀតថា មេធាវីការពារក្តីគួរមានឱកាសក្នុងការបង្ហាញពីចំណុចខុសគ្នាដែលអាចមានរវាងកំណត់ហេតុស្តាប់ចម្លើយ និង ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ទាំងនេះ ដើម្បីឆ្លើយតបទៅនឹងសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងនោះមកធ្វើជាភ័ស្តុតាង[9]។ ក្រោយបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ ការដាក់បង្ហាញខ្សែអាត់សំឡេងទាំងនេះក៏មានសារៈសំខាន់ដែរ នៅក្នុងការធ្វើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ដោយធ្វើការបង្ហាញចំណុចខុសគ្នារវាងខ្សែអាត់សំឡេង និង កំណត់ហេតុស្តាប់ចម្លើយដែលអាចមាន[10]។ ហេតុនេះ មេធាវីការពាក្តី ខៀវ សំផន ស្នើសុំឱ្យមានការដាក់បង្ហាញខ្សែអាត់សំឡេងទាំងនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ មេធាវីការពាក្តីក៏ស្នើសុំអង្គជំនុំជម្រះឱ្យផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យលើខ្សែអាត់សំឡេងទាំងនេះ ដើម្បីជាលទ្ធភាពក្នុងការស្វែងរកចំណុចខុសគ្នាដែលអាចមាន និង ដើម្បីពិចារណាថាតើខ្លួនគួរស្នើសុំកោះហៅសារជាថ្មីនូវបុគ្គលមួយចំនួនដែលធ្លាប់មកផ្តល់សក្ខីកម្មរួចមកហើយនោះ ឬ យ៉ាងណា[11]។ បន្ទាប់ពីខ្សែអាត់សំឡេងទាំងនោះត្រូវបានដាក់បង្ហាញរួចហើយ វាគួរត្រូវបានទទួលយកធ្វើជាភ័ស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ព្រោះខ្សែអាត់សំឡេងទាំងនេះមានប្រយោជន៍ក្នុងការស្វែងរកការពិត និង មានភាពជាប់ពាក់ព័ន្ធមិនអាចកាត់ផ្តាច់បានពីភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង[12]។

៥. ជាចុងក្រោយ មេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញាគួរទទួលទណ្ឌកម្ម ចំពោះការខកខានមិនបានដាក់បង្ហាញខ្សែអាត់សំឡេងទាំងនេះដល់ភាគី ដោយអនុលោមតាមវិធាន ៦៨*ស្ទួន* នៃ

[7] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៨-៩។

[8] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១០។

[9] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១១-១៣។

[10] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៣។

[11] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៣-១៤ និងជើងទំព័រ ១៤។

[12] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៤។

វិធានស្តីពីនីតិវិធី និង ភស្តុតាង នៃវិធាននីតិវិធីអន្តរជាតិដែលបានបង្កើតឡើងដោយតុលាការ ICTY[13]។ មេធាវីការពារក្តីទើបមានលទ្ធភាពក្នុងដាក់សំណើនេះ ដោយសារមូលហេតុនៃការខក ខានរបស់សហព្រះរាជអាជ្ញា[14]។ ភាពសន្មតទុកជាមុនដែលថាសហព្រះរាជអាជ្ញាបំពេញកាតព្វកិច្ច របស់ខ្លួនក្នុងការដាក់បង្ហាញឯកសារដោយសុចរិតភាពនោះ មិនអាចដោះស្រាយបានចំពោះការខក ខានជាច្រើនលើកច្រើនសារក្នុងការដាក់បង្ហាញខ្សែអាត់សំឡេងទាំងនេះ នោះឡើយ[15]។

## ២.២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

៦. សហព្រះរាជអាជ្ញាអន្តរជាតិ ពុំជំទាស់ទៅនឹងការដាក់បង្ហាញខ្សែអាត់សំឡេងដែលបានស្នើសុំដោយ មេធាវីការពារក្តី ខៀវ សំផន នោះឡើយ ហើយសហព្រះរាជអាជ្ញាអន្តរជាតិអះអាងទៀតថា ខ្លួន គាំទ្រចំពោះគោលការណ៍នៃការដាក់បង្ហាញដោយចំហ និង ប្រកបដោយតម្លាភាព ចំពោះរាល់ សម្ភារៈទាំងឡាយដែលមេធាវីការពារក្តី និង អង្គជំនុំជម្រះមានបំណងចង់ឲ្យដាក់បង្ហាញ។ ជាមួយ គ្នានោះផងដែរ សហព្រះរាជអាជ្ញាបានខិតខំប្រឹងប្រែងចំណាយពេលវេលាក្នុងការពិនិត្យមើលភស្តុ-តាងនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ក្នុងស្វែងរកសម្ភារៈដោះបន្ទុកផ្សេងៗទៀត[16]។ សហ-ព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងទៀតថា វាជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ បង្ហាញសម្ភារៈទាំងឡាយណា ដែលអាចប៉ះពាល់ដល់ភាពជឿជាក់បាននៃភស្តុតាងដទៃទៀត ហើយដោយសារតែមូលហេតុនេះ សម្ភារៈទាំងនោះត្រូវតែមានលក្ខណៈដោះបន្ទុក[17]។

៧. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា កាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់បង្ហាញសម្ភារៈគឺ កម្រិតត្រឹមតែសម្ភារៈទាំងឡាយណា ដែលខ្លួនបានដឹងយ៉ាងច្បាស់ថាមានលក្ខណៈដោះបន្ទុកតែ ប៉ុណ្ណោះ[18]។ យ៉ាងណាមិញ ដោយសារខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយត្រូវបានសាក្សីអាន និង បញ្ជាក់ឡើងវិញ ហេតុនេះវាពុំមានហេតុផលសមស្របដើម្បីធ្វើការសន្និដ្ឋានថាខ្សែអាត់សំឡេង

[13] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៦ និងជើងទំព័រ ១៦។

[14] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៦។

[15] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៦។

[16] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៦, ២៣។

[17] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៧។

[18] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៧។

ទាំងនេះមានខ្លឹមសារខុសគ្នាពីកំណត់ហេតុស្តាប់ចម្លើយនោះឡើយ[19]។ ដូចនេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាខ្លួនពុំមានការយល់ដឹងជាក់លាក់ថា ខ្សែអាត់សំឡេងទាំងនេះមានលក្ខណៈដោះបន្ទុកនោះឡើយ។

៨. ពេលនេះ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងការស្នើសុំឱ្យទទួលយករាល់ខ្សែអាត់សំឡេងទាំងនោះមកធ្វើជាភ័ស្តុតាង ដោយបានកត់សម្គាល់ថាខ្សែអាត់សំឡេងទាំងនោះអាចជាន់គ្នាជាមួយសម្ភារៈដទៃទៀតដែលមាននៅក្នុងសំណុំរឿងរួចមកហើយ ហើយវាពុំមានការបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងខ្សែអាត់សំឡេងទាំងនេះ និង កំណត់ហេតុស្តាប់ចម្លើយដែលជាប់ពាក់ព័ន្ធនោះឡើយ[20]។ កំណត់ហេតុស្តាប់ចម្លើយត្រូវបានសន្មតថាមានភាពជឿជាក់បានលុះត្រាតែមានភ័ស្តុតាងផ្ទុយពីការសន្មតនេះ[21]។ ជាមួយគ្នានេះផងដែរ វាត្រូវការប្រើពេលវេលា និង ធនធានដ៏ច្រើនរបស់ អ.វ.ត.ក នៅក្នុងការធ្វើប្រតិចារឹក និង ការបកប្រែខ្សែអាត់សំឡេងទាំងនោះទាំងស្រុង ដែលនេះគឺជាលក្ខខណ្ឌនៃដំណើរការនៅក្នុងការទទួលយកខ្សែអាត់សំឡេងទាំងនេះមកធ្វើជាភ័ស្តុតាង[22]។

៩. ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថាមេធាវីការពារក្តី ខៀវ សំផន មិនបានបង្ហាញថាសហព្រះរាជអាជ្ញាមានចេតនាទុច្ចរិត ដែលមិនបានជូនដំណឹងដល់មេធាវីការពារក្តីអំពីអត្ថិភាពនៃខ្សែអាត់សំឡេងនេះឡើយ។ នៅពេលដែលកិច្ចសម្ភាសន៍នៃការស្តាប់ចម្លើយ ត្រូវបានថតសំឡេង អត្ថិភាពនៃខ្សែអាត់សំឡេងគឺត្រូវបានគូសបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ហើយវាជាការបង្ហាញពីអត្ថិភាពនៃខ្សែអាត់សំឡេងដល់មេធាវីការពារក្តីរួចហើយ។ ទោះមេធាវីការពារក្តីមិនបានកត់សម្គាល់អំពីព័ត៌មាននេះក៏ដោយ ក៏ហេតុផលនេះមិនបង្ហាញពីភាពខកខានរបស់សហ-ព្រះរាជអាជ្ញាក្នុងការបំពេញកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសារនោះឡើយ[23]។

---

[19] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៨។

[20] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៩, ២៣។

[21] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៩។

[22] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២០។

[23] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២១-២២។

## ៣. ច្បាប់ជាធរមាន

១០. វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង បានផ្តល់កាតព្វកិច្ចបន្ថែមដល់សហព្រះរាជអាជ្ញា ក្នុងការដាក់បង្ហាញដល់ភាគី (តាមរយៈអង្គជំនុំជម្រះសាលាដំបូង) នូវសម្ភារៈទាំងឡាយ ដែលសហព្រះរាជ-អាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឱ្យនត្ថិភាពនៃពិរុទ្ធភាព ឬ សម្រាលពិរុទ្ធភាពដល់ជនជាប់ចោទ ឬធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់បាននៃភ័ស្តុតាងក្នុងការចោទប្រកាន់ ឬ ផ្សេងពីនេះ[24]។ កាតព្វកិច្ចក្នុងការដាក់បង្ហាញសម្ភារៈពីសំណុំរឿង ០០៣ និង ០០៤ ដែលមានលក្ខណៈដោះបន្ទុកត្រូវធ្លាក់ទៅសហព្រះរាជអាជ្ញា ព្រោះសហព្រះរាជអាជ្ញាមានសិទ្ធិចូលពិនិត្យមើលកិច្ចស៊ើបសួរដែលកំពុងដំណើរការនៅក្នុងសំណុំរឿងទាំងនោះ ចំណែកឯជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ មិនមានសិទ្ធិនេះឡើយ[25]។

១១. អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺថា សហព្រះរាជអាជ្ញាពុំចាំបាច់ធ្វើការសន្មតទៅលើការយល់ឃើញរបស់មេធាវីការពារក្តីនោះឡើយ ព្រោះកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា គឺកម្រិតត្រឹមតែការដាក់បង្ហាញនូវសម្ភារៈដែល "សហព្រះរាជអាជ្ញាបានដឹង" ថាមានលក្ខណៈដោះបន្ទុក[26]។ វាជាការទទួលខុសត្រូវផ្តាច់មុខរបស់សហព្រះរាជអាជ្ញា នៅក្នុងការសម្រេចដោយពឹងផ្អែកទៅលើចេតនាល្អរបស់សហព្រះរាជអាជ្ញាក្នុងការបំពេញការងារថា តើព័ត៌មានណាអាចជាព័ត៌មានដោះបន្ទុក[27]។

១២. ចម្លើយរបស់សាក្សីនៅក្នុងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ ដែលទទួលបាននៅក្នុងនីតិវិធីនៃកិច្ចស៊ើបសួររបស់ អ.វ.ត.ក ត្រូវបានសន្មតថាអាចជឿជាក់បាន ដោយសារកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះត្រូវបានរៀបចំក្រោមការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត ដោយមានការការពារចំពោះយថាភាព និង ភាពជឿជាក់បាន។ ជាពិសេស កំណត់ហេតុស្តាប់ចម្លើយដែលបាន

---

[24] ការជូនដំណឹងអំពីចម្លើយសាក្សី សម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ឯកសារ E127/4 ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកទីមួយស្តីពីការដាក់បង្ហាញឯកសារ")។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ឯកសារ E363/3 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើសំណើសុំកម្រិតការដាក់បង្ហាញឯកសារ") កថាខណ្ឌ ១៥-១៦។ សេចក្តីសម្រេចលើសំណើសុំស្តីពីកាលបរិច្ឆេទកំណត់ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E421/4 ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ("សេចក្តីសម្រេចស្តីពីកាលបរិច្ឆេទកំណត់នៃភ័ស្តុតាងថ្មី") កថាខណ្ឌ ៩។

[25] សេចក្តីសម្រេចស្តីពីកាលបរិច្ឆេទកំណត់សម្រាប់ដាក់ភ័ស្តុតាងថ្មី កថាខណ្ឌ ៩។

[26] សេចក្តីសម្រេចលើសំណើសុំកម្រិតការដាក់បង្ហាញឯកសារ កថាខណ្ឌ ២៤។

[27] សេចក្តីសម្រេចលើសំណើសុំកម្រិតការដាក់បង្ហាញឯកសារ កថាខណ្ឌ ២៤។

លើកឡើងនៅក្នុងដីកាដំណោះស្រាយ ហើយរៀបចំដោយសហចៅក្រមស៊ើបអង្កេត។ គេអាចជំទាស់ទៅនឹងការសន្មតនេះបានតែនៅពេលដែលភាគីផ្តល់នូវសំអាងហេតុហេតុពេញលេញ ដោយមានភស្តុតាងច្បាស់លាស់គាំទ្រដែលថា ចម្លើយដែលបានលើកឡើងនោះពុំអាចជឿជាក់បាន ឬ មិនសុក្រឹត្យ[28]។

១៣. អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិចារណាទៅតាមបញ្ហាចោទឡើងជាក់ស្តែងនីមួយៗ នៅក្នុងការធ្វើសក្ខីកម្មរបស់សាក្សីនៅក្នុងសវនាការ ដោយផ្អែកលើចំណុចមិនស៊ីសង្វាក់គ្នារវាងចម្លើយពីមុនរបស់សាក្សី និង ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ បើសិនជាមាន។ ទោះបីយ៉ាងនេះក្តី អង្គជំនុំជម្រះនឹងពិចារណាទៅលើការចោទប្រកាន់អំពីចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេង និង កំណត់ហេតុស្តាប់ចម្លើយ នៅពេលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចមិនស៊ីសង្វាក់គ្នានេះ ហើយនៅពេលភាពមិនស៊ីសង្វាក់គ្នានោះ ទាក់ទិននឹងចំណុចខ្វះចន្លោះនៃខ្លឹមសារដែលត្រូវបានចោទប្រកាន់ ដែលមានភាពពាក់ព័ន្ធជាក់ស្តែងទៅនឹងការជំនុំជម្រះ។ លើសពីនេះ ភាគីណាមួយដែលលើកការជំទាស់ ត្រូវមានបន្ទុកបង្ហាញឲ្យបានច្បាស់លាស់នូវចំណុចមិនស៊ីសង្វាក់គ្នាដែលត្រូវបានចោទប្រកាន់ និង ជូនដំណឹងឲ្យបានទាន់ពេលវេលាមកអង្គជំនុំជម្រះ និង ភាគីដទៃទៀតអំពីការចោទប្រកាន់ទាំងអស់នេះ និង ឯកសារពាក់ព័ន្ធ។ ដើម្បីបញ្ចៀសការដាក់បន្ទុកលើសលប់ចំពោះអង្គភាពរបស់តុលាការដែលទទួលខុសត្រូវលើការបកប្រែ និង ការធ្វើប្រតិចារឹក ចំពោះសម្ភារៈដ៏ច្រើន ដែលភាពពាក់ព័ន្ធរបស់វាទៅនឹងការជំនុំជម្រះពុំទាន់ត្រូវបានបង្ហាញ អង្គជំនុំជម្រះធ្លាប់បានជូនដំណឹងថា សំណើសុំធ្វើប្រតិចារឹក និង សំណើសុំបកប្រែដើម្បីគាំទ្រសេចក្តីជំទាស់ទាំងនេះ ត្រូវបង្ហាញឲ្យបានជាក់លាក់នូវចំណុចមិនស៊ីសង្វាក់គ្នា និង កំហិតត្រឹមផ្នែកនានានៃចម្លើយ និង ខ្សែអាត់សំឡេងពាក់ព័ន្ធ ដែលត្រូវបានចោទប្រកាន់ថាមានចំណុចមិនស៊ីសង្វាក់គ្នាប៉ុណ្ណោះ។ ហេតុនេះ អង្គជំនុំជម្រះនឹងមិនពិចារណាលើសំណើសុំធ្វើប្រតិចារឹក និង សំណើសុំបកប្រែខ្សែអាត់សំឡេង ឬ ប្រតិចារឹក ទាំងស្រុងក្នុងចំនួនដ៏ច្រើននោះឡើយ[29]។

---

[28] សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ឯកសារ E251 ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២២។

[29] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ឯកសារ E142/3 ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ ("សេចក្តីសម្រេចស្តីពីភាពមិនស៊ីសង្វាក់គ្នានៃខ្សែអាត់សំឡេង" កថាខណ្ឌ ១២។

# ៤. សំអាងហេតុ

## ៤.១ សំណើសុំឲ្យដាក់បង្ហាញ និង ទទួលយកខ្សែអាត់សំឡេង

១៤. អង្គជំនុំជម្រះ មិនយល់ស្របទៅនឹងការអះអាងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ ដែលត្រូវបានធ្វើជាកំណត់ហេតុស្តាប់ចម្លើយរបស់តុលាការគួរត្រូវបានចាត់ទុកជាភ័ស្តុតាងដោះបន្ទុកដោយស្វ័យប្រវត្តិស្របតាមខ្លឹមសារនៃវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុងនោះឡើយ។ អង្គជំនុំជម្រះធ្លាប់កត់សម្គាល់ពីមុនរួចមកហើយថា កំណត់ហេតុស្តាប់ចម្លើយ ត្រូវបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលជាស្ថាប័នឯករាជ្យ និង មិនលម្អៀងមួយរបស់តុលាការ។ លើសពីនេះទៀត នៅពេលបញ្ចប់កិច្ចសម្ភាសន៍នៃការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្នើឲ្យពិនិត្យឡើងវិញលើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយ និងបញ្ជាក់ពីភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយនោះ។ ហេតុនេះ កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ត្រូវបានសន្មតជាមុនថាគួរជឿជាក់បាន ហើយវាមិនមានមូលដ្ឋានក្នុងការប៉ាន់ប្រមាណថាខ្សែអាត់សំឡេងទាំងនោះខុសគ្នាខ្លាំងពីកំណត់ហេតុស្តាប់ចម្លើយនោះឡើយ។ ដូចនេះ អង្គជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញាពុំមានកាតព្វកិច្ចក្នុងការត្រួតពិនិត្យលើចំណុចមិនស៊ីសង្វាក់គ្នារវាងចម្លើយដែលមានក្នុងកំណត់ហេតុស្តាប់ចម្លើយ និង ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយទាំងនេះនោះឡើយ។ អង្គជំនុំជម្រះយល់ឃើញថា វាមិនមានភ័ស្តុតាងណាមួយដែលបានបង្ហាញថាសហព្រះរាជអាជ្ញាបានយល់ដឹងជាក់ច្បាស់ថាខ្សែអាត់សំឡេងទាំងនេះ មានភ័ស្តុតាងដោះបន្ទុកនោះឡើយ។ អាស្រ័យហេតុនេះ អនុលោមតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាមិនមានកាតព្វកិច្ចក្នុងការដាក់បង្ហាញខ្សែអាត់សំឡេងទាំងនេះជាស្វ័យប្រវត្តិនោះទេ។

១៥. ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានបង្ហាញថា អង្គជំនុំជម្រះនឹងពិចារណាទៅលើរាល់ការចោទឡើងលើចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ និង កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខអក្សរនៅពេលដែលចំណុចមិនស៊ីសង្វាក់ទាំងនោះត្រូវបានកំណត់ច្បាស់លាស់ហើយភាពខ្វះចន្លោះនៃខ្លឹមសារដែលត្រូវបានចោទប្រកាន់មានជាប់ពាក់ព័ន្ធទៅនឹងការជំនុំជម្រះ[30]។ ជាក់ស្តែង ការបង្ហាញនេះអាចធ្វើបានបន្ទាប់ពីការស្តាប់ខ្សែអាត់សំឡេង ដែលនេះតម្រូវឲ្យមានការ

[30] សេចក្តីសម្រេចលើភាពមិនស៊ីសង្វាក់គ្នានៃខ្សែអាត់សំឡេង កថាខណ្ឌ ១២។

ចូលមើលសម្ភារៈទាំងនេះ[31]។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីគួរមានឱកាសក្នុងការពិនិត្យខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង កំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤ ដែលបានទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ រួចមកហើយ។

១៦. អាស្រ័យដោយហេតុថា មេធាវីការពារក្តីមិនមានលទ្ធភាពក្នុងការចូលមើលសំណុំរឿង ០០៣ និង ០០៤ បាន មេធាវីការពារក្តីត្រូវទទួលបានការជូនដំណឹងពីអត្ថិភាពនៃខ្សែអាត់សំឡេងទាំងនេះ។ ក្នុងករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តីបានទទួលការជូនដំណឹងតាំងពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ពីអត្ថិភាពនៃខ្សែអាត់សំឡេងសម្រាប់កំណត់ហេតុស្តាប់ចម្លើយមួយចំនួនដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤។ កំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានដាក់បង្ហាញដល់មេធាវីការពារក្តី តាមរយៈការគូសក្នុងប្រអប់មួយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ដែលបង្ហាញថាតើ ការស្តាប់ចម្លើយនោះត្រូវបានថតសំឡេង ឬ វីដេអូដែរ ឬយ៉ាងណា។ ប្រអប់នេះត្រូវបានគូសនៅកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ៦១ យ៉ាងតិចដែលត្រូវបានទទួលយកធ្វើជាភ័ស្តុតាងរួចមកហើយ ឬ ត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២[32]។ កំណត់ហេតុស្តាប់ចម្លើយចំនួន ១៤ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ត្រូវបានដាក់បង្ហាញដល់មេធាវីការពារក្តី នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ហើយត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាង នៅខែ ឧសភា ឆ្នាំ ២០១៥[33]។ ទោះបីជាការដាក់បង្ហាញកំណត់ហេតុការស្តាប់ចម្លើយចំនួន ១៤ គឺការបង្ហាញឯកសារដ៏ច្រើនសម្បើមក៏ដោយ តែ

---

[31] *ប្រៀបធៀប* វិធាននីតិវិធី និង ភ័ស្តុតាងនៅតុលាការ ICTY វិធាន ៦៦ខ ("បន្ទាប់ពីមានសំណើ រដ្ឋអាជ្ញាត្រូវអនុញ្ញាតឱ្យមេធាវីការពារក្តីធ្វើការពិនិត្យទៅលើសៀវភៅ ឯកសារ រូបថត និង វត្ថុរូបីយ៍ដែលស្ថិតក្នុងការថែរក្សា និង ការគ្រប់គ្រងរបស់រដ្ឋអាជ្ញា ដែលជាសម្ភារៈដើម្បីរៀបចំសម្រាប់ការការពារក្តី ឬ ដែលរដ្ឋអាជ្ញាមានបំណងយកមកប្រើប្រាស់ជាភ័ស្តុតាងនៅពេលជំនុំជម្រះ ឬ ត្រូវបានទទួលពីជនជាប់ចោទ ឬ ជាកម្មសិទ្ធិរបស់ជនជាប់ចោទ")។

[32] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៣។ អង្គជំនុំជម្រះបានស្នើសុំឱ្យសហព្រះរាជអាជ្ញាដាក់បញ្ជីនេះ ដើម្បីជួយក្នុងការរៀបរៀងសេចក្តីសម្រេចនេះ។ អង្គជំនុំជម្រះភ្ជាប់តារាងដែលបានកែសម្រួលជាមួយសេចក្តីសម្រេចនេះ។ ភាគីអាចរកព័ត៌មាននេះបាន បន្ទាប់ពីបានពិនិត្យកំណត់ហេតុស្តាប់ចម្លើយនីមួយៗ។

[33] ឯកសារ E319/19.3.3; E319/19.3.58; E319/19.3.55; E319/19.3.56; E319/19.3.2; E319/19.3.54; E319/19.3.61; E319/19.3.57; E319/19.3.73; E319/19.3.1; E319/19.3.53; E319/19.3.219; E319/19.3.65; E319/19.3.217។ កំណត់ហេតុស្តាប់ចម្លើយផ្សេងទៀតត្រូវបានថតសំឡេង ត្រូវបានដាក់បង្ហាញជាចុងក្រោយនៅខែ មិថុនា ឆ្នាំ ២០១៥, ខែ មករា ឆ្នាំ ២០១៦, ខែ មេសា ឆ្នាំ ២០១៦, ខែ កក្កដា ឆ្នាំ ២០១៦, ខែ សីហា ឆ្នាំ ២០១៦ និង ខែ កញ្ញា ឆ្នាំ ២០១៦។

កិច្ចដំណើរការនីតិវិធីជំនុំជម្រះបានផ្អាករយៈពេលមួយសប្តាហ៍ ដើម្បីឱ្យភាគីពិនិត្យមើលលើឯកសារដែលដាក់បង្ហាញទាំងនោះបាន[34]។ មេធាវីការពារក្តីក៏ទទួលបានពេលគ្រប់គ្រាន់ នៅក្នុងអំឡុងពេល ១៨ ខែបន្ទាប់មកផងដែរ ក្នុងការពិនិត្យលើកំណត់ហេតុស្តាប់ចម្លើយ និង កំណត់ថាតើកំណត់ហេតុស្តាប់ចម្លើយណាខ្លះត្រូវបានថតសំឡេង។ ជាងនេះទៀត យ៉ាងហោចណាស់មានខ្សែអាត់សំឡេងចំនួនបួននៅក្នុងចំណោមខ្សែអាត់សំឡេងទាំងនេះ ត្រូវបានធ្វើជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ដែលមេធាវីការពារក្តី ខៀវ សំផន អះអាងថាខ្លួនបានពិនិត្យកំណត់ហេតុទាំងនោះរួចហើយ[35]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា មេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់គឺចាប់តាំងពីខែ មីនា ឆ្នាំ ២០១៥ មកម្ល៉េះ ក្នុងការស្វែងរក និង ស្នើសុំខ្សែអាត់សំឡេងដែលខ្លួនបានដឹងទាំងនោះ។ នៅក្នុងករណីនេះផងដែរ សហព្រះរាជអាជ្ញាបានបំពេញកាតព្វកិច្ចរបស់ខ្លួនរួចហើយ ដែលកាតព្វកិច្ចនេះមិនហួសពីការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤ ទាំងឡាយណាដែលទំព័រមុខនៃកំណត់ហេតុទាំងនោះ មានបញ្ជាក់បង្ហាញថាតើកិច្ចសម្ភាសន៍ទាំងនោះត្រូវបានថតសំឡេង ឬយ៉ាងណា។

១៧. ទាក់ទិននឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យទទួលយកខ្សែអាត់សំឡេងធ្វើជាភស្តុតាង អង្គជំនុំជម្រះយល់ឃើញថា ជាការឆាប់រហ័សពេកនៅក្នុងដំណើការនៃនីតិវិធី។ មេធាវីការពារក្តីនឹងមានឱកាសក្នុងការពិនិត្យខ្សែអាត់សំឡេង ដែលបានដាក់បង្ហាញទាំងនោះ និង ធ្វើការកំណត់រាល់ចំណុចមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ និង កំណត់ហេតុស្តាប់ចម្លើយទាំងនេះ។ ប្រសិនបើមានចំណុចមិនស៊ីសង្វាក់គ្នានៅត្រង់ផ្នែកពាក់ព័ន្ធណាមួយនៃខ្សែអាត់សំឡេងទាំងនោះ ចំណុចមិនស៊ីសង្វាក់ទាំងនោះចាំបាច់ត្រូវយកមកធ្វើជាប្រតិចារឹក បកប្រែ និង ទទួលយកធ្វើជាភស្តុតាង[36]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីពុំបានបង្ហាញពីភាពចាំបាច់ក្នុងការទទួលយករាល់ខ្សែអាត់សំឡេងដែលមានអត្ថិភាពទាំងនេះមកធ្វើ

---

[34] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ២៩-៣១។

[35] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ (សក្ខីកម្មរបស់ តក់ ប៊ុយ); ប្រតិចារឹកសវនាការ ថ្ងៃទី ១១ និង ទី ១២ ខែ មករា ឆ្នាំ ២០១៦ (សក្ខីកម្មរបស់ មុយ វ៉ាន់នី); ប្រតិចារឹកសវនាការ ថ្ងៃទី ៥ និង ទី ៦ ខែ តុលា ឆ្នាំ ២០១៥ (សក្ខីកម្មរបស់ បាន សៀក); ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សក្ខីកម្មរបស់ ប៉ាន ឈ្មួង); ប្រតិចារឹកសវនាការ ថ្ងៃទី ១ និង ទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ (សក្ខីកម្មរបស់ ប៉ាន ឈ្មួង); សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៨-៩។

[36] សេចក្តីសម្រេចលើភាពមិនស៊ីសង្វាក់គ្នានៃខ្សែអាត់សំឡេង កថាខណ្ឌ ១២។

ជាភ័ស្តុតាងនោះទេ នៅពេលដែលមេធាវីការពារក្តី និង អង្គជំនុំជម្រះមិនទាន់ទាំងមានឱកាសក្នុងការពិនិត្យលើខ្សែអាត់សំឡេងទាំងនោះផង។

១៨. មេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងថាមេធាវីការពារក្តីគួរមានឱកាសក្នុងការជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយធ្វើជាភ័ស្តុតាង ដោយផ្អែកលើចំណុចមិនស៊ីសង្វាក់គ្នាដែលអាចមាននៅក្នុងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយដែលបានដាក់បង្ហាញ[37]។ ដូចដែលបានកត់សម្គាល់ខាងលើ មេធាវីការពារក្តីបានទទួលការជូនដំណឹងតាំងពីខែ មីនា ឆ្នាំ ២០១៥ ពីអត្ថិភាពនៃខ្សែអាត់សំឡេងទាំងនេះ។ អង្គជំនុំជម្រះធ្លាប់បានឯកភាពចំពោះសំណើរបស់មេធាវីការពារក្តីសុំពន្យារពេលរហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដើម្បីឆ្លើយតបទៅនឹងសំណើចុងក្រោយរបស់សហព្រះរាជអាជ្ញាដែលសុំអង្គជំនុំជម្រះឱ្យទទួលយកឯកសារមួយចំនួនធ្វើជាឯកសារភ័ស្តុតាង រួមទាំងកំណត់ហេតុស្តាប់ចម្លើយជាច្រើនដែលកំពុងពិភាក្សានៅពេលនេះ[38]។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់ក្នុងការស្នើសុំខ្សែអាត់សំឡេងដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការដោះបន្ទុក។ អង្គជំនុំជម្រះបដិសេធលើការលើកយកមកពិភាក្សាជាថ្មី និង ការពន្យារពេលកំណត់បន្ថែមសម្រាប់ការដាក់ចម្លើយតបទាក់ទិននឹងការទទួលយកធ្វើជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយដែលផ្អែកលើព័ត៌មានដែលអាចមាននៅក្នុងខ្សែអាត់សំឡេងទាំងនោះ។ ជាចុងក្រោយ ដូចបានកត់សម្គាល់ពីមុនមក ការសន្មតលើភាពជឿជាក់បាន និង យថាភាពនៃកំណត់ហេតុស្តាប់ចម្លើយ បានបំពេញតាមការបញ្ជាក់បឋមនៃការទទួលយកភ័ស្តុតាង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងពិចារណាលើរាល់សេចក្តីសន្និដ្ឋានដែលមេធាវីការពារក្តីបានដាក់ ដែលផ្អែកលើចំណុចខុសគ្នាដែលអាចមានរវាងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ និង កំណត់ហេតុស្តាប់ចម្លើយ ហើយអង្គជំនុំជម្រះនឹងធ្វើការពិចារណា ថាតើគួរផ្តល់តម្លៃជាភ័ស្តុតាងកំរិតណាចំពោះកំណត់ហេតុស្តាប់ចម្លើយទាំងនោះ។

១៩. ទោះបីជាមេធាវីការពារក្តីស្នើសុំឱ្យមានពេលវេលាសមស្របគ្រប់គ្រាន់ ដើម្បីពិនិត្យលើខ្សែអាត់សំឡេងយ៉ាងណាក៏ដោយ តែមេធាវីការពារក្តី មិនបានដាក់សេចក្តីសន្និដ្ឋានណាមួយពាក់ព័ន្ធនឹងថា

---

[37] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ១៣។

[38] សេចក្តីសម្រេចលើសំណើនានាពាក់ព័ន្ធនឹងពេលវេលាកំណត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E421/3 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦; សេចក្តីសម្រេចលើសំណើសុំស្តីពី កាលបរិច្ឆេទកំណត់ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង [សំអាងហេតុទាំងស្រុង] ឯកសារ E421/4 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦។

តើពេលវេលាប៉ុន្មានដែលមេធាវីការពារក្តីត្រូវការនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពន្យារពេលក្នុងការសម្រេចថាតើពេលវេលាបន្ថែមប៉ុន្មានទើបមានភាពសមរម្យ។

## ៤.២. សំណើសុំដាក់ទណ្ឌកម្ម

២០. អង្គជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញា មិនមានកាតព្វកិច្ចក្នុងការដាក់បង្ហាញដល់មេធាវីការពារក្តីដោយស្វ័យប្រវត្តិនូវរាល់អត្ថិភាពនៃខ្សែអាត់សំឡេងដែលត្រូវបានធ្វើជាកំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាង ឬត្រូវបានទទួលយកធ្វើជាភ័ស្តុតាងរួចមកហើយនោះឡើយ។ ចំពោះកាតព្វកិច្ចក្នុងការជូនដំណឹងស្តីពីអត្ថិភាពនៃខ្សែអាត់សំឡេងទាំងឡាយត្រូវចាត់ទុកថាបានបំពេញរួចហើយ នៅពេលដែលសហព្រះរាជអាជ្ញាបង្ហាញថាតើកំណត់ហេតុស្តាប់ចម្លើយនោះត្រូវបានថតជាសំឡេងដែរ ឬ យ៉ាងណា។ ហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើសុំឱ្យដាក់ទណ្ឌកម្មលើសហព្រះរាជអាជ្ញា។

## ៤.៣. ការអនុញ្ញាតឱ្យដាក់បង្ហាញ

២១. អង្គជំនុំជម្រះកត់សម្គាល់ថា នាពេលនេះសំណើសុំ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង កំពុងរង់ចាំការសម្រេចក្នុងការទទួលយកខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយមួយចំនួនក្នុងសំណុំរឿង ០០៣ និង ០០៤ ធ្វើជាភ័ស្តុតាង[39]។ ដោយកត់សម្គាល់ថា ខ្សែអាត់សំឡេងចំនួនបួនបានទទួលការអនុញ្ញាតឱ្យដាក់បង្ហាញរួចមកហើយ និងដើម្បីកាត់បន្ថយបន្ទុកការងាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការពិនិត្យទៅលើសំណើជាច្រើនដែលស្នើសុំការអនុញ្ញាតឱ្យដាក់បង្ហាញខ្សែអាត់សំឡេងនោះ[40] អង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាសុំការអនុញ្ញាតពី

---

[39] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E319/52 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦; សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E319/56 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦; សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារពីសំណុំរឿង ០០៣ និង ០០៤ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E319/58 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦។

[40] ការអនុញ្ញាតដាក់បង្ហាញខ្សែអាត់សំឡេងពីសំណុំរឿង ០០៤ កថាខណ្ឌ ៩ ("ទោះជាយ៉ាងណាក្តី ខ្ញុំពិតជាកត់សម្គាល់ថាសំណើសុំឱ្យទទួលយកខ្សែអាត់សំឡេងតែមួយនេះត្រូវបានទទួលយក ដោយផ្អែកលើករណីពិសេស។ ខ្ញុំតម្រូវឱ្យ ក.ស.ព ដាក់សំណើបន្ថែមក្នុងការស្នើសុំខ្សែអាត់សំឡេងដែលមានលក្ខណៈទូលំទូលាយជាងមុន និង ក្រោយពេលបានធ្វើការស្រាវជ្រាវ និងវិភាគយ៉ាងលម្អិតទៅលើសម្ភារៈជាសំឡេងដែលមាននៅចំពោះមុខពួកគេ")។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការដាក់បង្ហាញរាល់ខ្សែអាត់សំឡេងនៃកំណត់ហេតុស្តាប់ចម្លើយទាំងឡាយ ដែលបានទទួលយកធ្វើជាភស្តុតាងរួចមកហើយ ឬ ត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២[41]។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**បង្គាប់** ឱ្យសហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង ដាក់បង្ហាញខ្សែអាត់សំឡេងនៃកំណត់ហេតុស្តាប់ចម្លើយសំណុំរឿង ០០៣ និង ០០៤ ទាំងអស់ ដែលត្រូវបានទទួលយកធ្វើជាភស្តុតាងរួចមកហើយ ឬ ត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។

**បដិសេធ** សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យទទួលយករាល់គ្រប់ខ្សែអាត់សំឡេងទាំងអស់ធ្វើភស្តុតាង បន្ទាប់ពីខ្សែអាត់សំឡេងទាំងនោះត្រូវបានដាក់បង្ហាញ ដោយមិនប៉ះពាល់ដល់សំណើក្រោយៗ ដែលសុំឱ្យទទួលយកធ្វើជាភស្តុតាងនូវផ្នែកជាក់លាក់នៃខ្សែអាត់សំឡេង ដែលមានបង្ហាញថាកំណត់ហេតុស្តាប់ចម្លើយនោះ មិនអាចជឿជាក់បាន ឬ មិនមានភាពត្រឹមត្រូវ។

**បដិសេធ** សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យដាក់ទណ្ឌកម្មលើសហព្រះរាជអាជ្ញាចំពោះការបំពានកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសារ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. E.C.C.C.

**និល ណុន**

[41] អង្គជំនុំជម្រះកត់សម្គាល់ថា ផ្នែកតិចតួចទាក់ទិននឹងការលះបង់សិទ្ធិមានវត្តមានមេធាវីត្រូវបានថតសំឡេងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ 2-TCCP-223 (ឯកសារ E3/9477 ទំព័រ ២)។ ខ្សែអាត់សំឡេងនេះក៏ត្រូវបានដាក់បង្ហាញដែរ។